**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន

នៅក្នុងជំនួបពិភាក្សាការងារជាមួយលោក Graeme Buckley នាយកការិយាល័យអង្គការអន្តរជាតិខាងការងារ (ILO) ប្រចាំប្រទេសកម្ពុជា ឡាវ និងថៃ នៅទីស្តីការក្រសួង នាព្រឹកថ្ងៃសុក្រ ៩រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨នេះ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានលើកឡើងពីវឌ្ឍនភាព នៃកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូជាមួយអង្គការអន្តរជាតិខាងការងារ ដែលរហូតមកទល់ពេលនេះ យើងទទួលបានសមិទ្ធផលជាផ្លែផ្កាជាច្រើនដូចជាការធានាបាននូវលក្ខខណ្ឌការងារល្អ សិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ការរៀបចំនូវបទដ្ឋាននានាបន្ថែមទៀត ដើម្បីធានាដល់ការអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពនូវច្បាប់ស្តីពីសហជីព និងការត្រៀមរៀបចំបន្តកម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជាពីឆ្នាំ២០១៩-២០២៣។

នាឱកាសនោះដែរ លោក Graeme Buckley បានសម្តែងនូវការស្វាគមន៍ និងអបអរសាទរនូវវឌ្ឍនភាពទាំងអស់នេះ ដែលកម្ពុជាខិតខំប្រឹងប្រែងអនុវត្តប្រកបដោយឆន្ទៈមុះមុតក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះសម្រេចបានជោគជ័យ។ លោកក៏បានសាទរចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានអនុវត្តប្រកបដោយជោគជ័យនូវក្របខណ្ឌគោលនយោបាយគាំពារសង្គម និងការរៀបចំឱ្យមានវិសោធនកម្មច្បាប់ស្តីពីការងារ ដើម្បីកែសម្រួលបញ្ញត្តិមាត្រា៨៩ ស្តីពីការទូទាត់ប្រាក់បំណាច់បណ្តេញចេញ និងមាត្រាពាក់ព័ន្ធនៃច្បាប់ស្តីពីការងារ ក្នុងគោលបំណងរក្សាផលប្រយោជន៍ជូនកម្មករនិយោជិត និងនិយោជក។ អង្គការ ILO នឹងបន្តជួយដល់សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម ហើយលោកនាយក ក៏រីករាយបន្តរួមសហការជាមួយនឹងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើឱ្យសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈនៅកម្ពុជាកាន់តែមានភាពល្អប្រសើរបន្តទៀត។

នៅក្នុងឆ្នាំ២០១៩ ខាងមុខនេះ ភាគីទាំងពីរបានឯកភាពក្នុងការត្រៀមរៀបចំឱ្យមានជាព្រឹត្តការណ៍ដ៏ធំមួយនៅកម្ពុជា សម្រាប់អបអរសាទរពិធីប្រារព្ធខួបអនុស្សាវរីយ៍១០០ឆ្នាំ នៃការបង្កើតអង្គការអន្តរជាតិខាងការងារ (១៩១៩-២០១៩) និងខួប៥០ឆ្នាំ(១៩៦៩-២០១៩) នៃការចូលជាសមាជិកអង្គការអន្តរជាតិខាងការងាររបស់កម្ពុជា ដើម្បីបង្ហាញឱ្យឃើញពីសមិទ្ធផលនានា ដែលកើតចេញពីកិច្ចសហប្រតិបត្តិការប្រកបដោយភាពជាដៃគូនេះដូចជាការរីកចម្រើននៃសិទ្ធិការងារ សិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ សិទ្ធិសេរីភាពក្នុងការបង្កើតសមាគម ព្រមទាំងបង្ហាញឱ្យឃើញផងដែរនូវផលលាភដែលបានរួមចំណែកដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិរបស់កម្ពុជា។

ថ្ងៃសុក្រ ៩រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩